# របាយការណ៍ស្តីពីការត្រួតពិនិត្យបរិស្ថាន និងសង្គម
# ក្រុមហ៊ុនហ្វ្រេនឌីស ធីមបើរ អិលធីឌី

ពីខែមិថុនា ដល់ ធ្នូ ឆ្នាំ២០២០

## ១. សេចក្តីផ្តើម

ក្រុមហ៊ុនហ្វ្រេនឌីស ធីមបើរ អិលធីឌី ជាក្រុមហ៊ុនបរទេសទទួលបានថវិកាវិនិយោគពីប្រទេសដាណាម៉ាក់ បានទទួលសិទ្ធិស្របច្បាប់សម្រាប់ការវិនិយោគសម្បទានដីសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា តាមកិច្ចសន្យា ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ និងកិច្ចសន្យាកែតម្រូវចុះ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ លើផ្ទៃដីទំហំ ៧.៨៩៦,១១ហិកតា ស្ថិតនៅក្នុងភូមិសាស្រ្ត ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ តំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនបានចុះបញ្ជីដីរដ្ឋ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនៅឆ្នាំ២០១៦ និងបានបញ្ចប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩។

តាមរយៈរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ និងកិច្ចសន្យាការពារបរិស្ថាន និងសង្គម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមហ៊ុនហ្វ្រេនឌីស ធីមបើរ អិលធីឌី ធានាទទួលខុសត្រូវ និងអនុវត្តនូវខ្លឹមសារ ដែលបានរៀបរាប់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) សម្រាប់គម្រោងដាំដើមម៉ៃសាក់ដែលក្រសួងបានឯកភាព។ ក្នុងជំពូកទី៨ កម្មវិធីអង្កេតតាមដានបរិស្ថានបញ្ជាក់ថា ក្រុមហ៊ុនម្ចាស់គម្រោងត្រូវធ្វើការត្រួតពិនិត្យ ឬអង្កេតតាមដានគម្រោងដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គមឱ្យដល់កម្រិតអប្បរមា។ កម្មវិធីអង្កេតតាមដានបរិស្ថាននេះផ្តោតសំខាន់លើធនធានបរិស្ថានរូបសាស្រ្ត ធនធានជីវសាស្រ្ត និងធនធានសង្គម ហើយសូចនករសំខាន់ៗសម្រាប់ធ្វើការវាយតម្លៃផលហេតុប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមនៅក្នុងតំបន់ត្រូវបានកំណត់។

របាយការាណ៍ពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជាក់ពីការតាំងចិត្ត ឬឆន្ទៈការពារបរិស្ថាន ដើម្បីបញ្ចៀសហេតុផលប៉ះពាល់អវិជ្ជមានឲ្យនៅកម្រិងអប្បរមានៅអំឡុងពេលអភិវឌ្ឍរបស់គម្រោង។ បាយការណ៍នេះ នឹងដាក់ជូននាយកដ្ឋានអង្កេត ត្រួតពិនិត្យ និងវាយតម្លៃហេតុផលប៉ះពាលបរិស្ថាន និងសង្គម នៃក្រសួងបរិស្ថានដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ណែនាំតាមបទដ្ឋានច្បាប់ បច្ចេកទេស និងការអនុវត្តជាក់ស្តែង ដើម្បីកែតម្រូវបន្ថែម។

### ១.១ គោលបំណង

ការត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន មានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ដើម្បីកំណត់ពីផលប៉ះពាល់សំខាន់ៗដែលអាចនឹងកើតមានឡើងនៅក្នុងការអនុវត្តគម្រោង
- បង្កើតកម្មវិធីការពារ កែតម្រូវ ដើម្បីកាត់បន្ថយហេតុផលប៉ះពាល់ឲ្យនៅត្រឹមកម្រិតអប្បរមា
- ដើម្បីធានាការអនុវត្តគម្រោង និងការថែទាំចម្ការឈើ អនុលោមតាមផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ដែលក្រសួងបានឯកភាព។

## ២. វិធីសាស្រ្តនៃការវាយតម្លៃ

ការអង្កេតជាក់ស្តែងនៅលើទីវាល ត្រូវបានប្រើប្រាស់ដើម្បីការកំណត់នូវហេតុផលប៉ះពាល់ជាអវិជ្ជមាន នៅតាមចន្លោះរងដាំឈើ ផ្លូវក្នុងតំបន់គម្រោង ព្រៃរក្សាទុកតាមដងអូរ ការប្រើប្រាស់ដី និងថ្នាំកសិកម្ម ការស្តុកសំណល់រឹងរាវ ទឹកបរិភោគរបស់បុគ្គលិកកម្មករ ព្រំដីបានចុះបញ្ជី ប្រភពទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋ ការិយាល័យរដ្ឋបាលក្រុមហ៊ុន ទីតាំងស្នាក់នៅរបស់បុគ្គលិក-កម្មករ ផ្លូវចេញចូលរបស់គម្រោងទាំងអស់ កន្លែងជួសជុលផ្លូវ

ទីតាំងចំណតយានយន្តនិងគ្រឿងចក្រ រោងជាង ឃ្លាំង ទីតាំងកន្លែងងកំពុងធ្វើការក្នុងអនុតំបន់ទាំង២៣ ប៉មយាមភ្លើង ជាពិសេសនៅរដូវប្រាំង និងថ្នាលបណ្តុះកូនឈើ។ ការអង្កេតតាមដាន ឬ ដោយប្រើប្រាស់បញ្ជីពិនិត្យ និងផ្ទៀងផ្ទាត់ជាក់ស្តែងនៅទីវាល។ លទ្ធផលនៃការត្រួតពិនិត ឬអង្កេតតាមដាន ត្រូវកាត់ត្រាដោយប្រប្រាស់បញ្ជីត្រួតពិនិត្យ (Checklist) និងឆ្លើយតបប្រធានផ្នែកបច្ចេកទេសនីមួយៗដើម្បីទទួលធាតុចូលបន្ថែមលើវិធានការបន្ត។

## ៣. លទ្ធផលនៃវាយតម្លៃ

នៅក្នុងតារាងខាងក្រោមនេះ (តារាងទី១) គឺជាលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុនហ្វែនឌីស ធីមប៊ើរ អិលធីឌី ក្នុងដំណាក់កាលអនុវត្តគម្រោងដាំឈើម៉ៃសាក់។

## ៤. ការគំរាមកំហែង និងដំណោះស្រាយ

ដូចបានបញ្ជាក់នៅក្នុងតារាងលទ្ធផលនៃការវាយតម្លៃនៅលើទីវាល (តារាងទី១) ក្រុមហ៊ុនហ្វ្រែនឌីស ធីម ប៊ើរ អិលធីឌី បានអនុវត្តគម្រោងវិនិយោគ ដោយយកចិត្តទុកដាក់លើការការពារបរិស្ថាន និងសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននូវមានចំណុចខ្វះខាតបន្តិចបន្តួច បានរកឃើញក្នុងពេលធ្វើការវាយតម្លៃ ដែលនឹងត្រូវធ្វើការកែតម្រូវ ដោយអនុឡោមតាមសូចនករ ដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។ តារាងខាងក្រោមបង្ហាញពីចំណុចខ្វះខាត និងលទ្ធភាពដោះស្រាយក្នុងរយៈពេលខ្លី និងរយៈពេលវែង (តារាងទី២)៖

*តារាងទី២៖ ការគំរាមកំហែង និងដំណោះស្រាយលើផលប៉ះពាល់បរិស្ថាន*

| ល.រ | កត្តាគំរាមកំហែងបរិស្ថាន | លទ្ធភាពក្នុងការដោះស្រាយ | |
|---|---|---|---|
| | | **រយៈពេលខ្លី** | **រយៈពេលវែង** |
| ១ | តំបន់ការពារប្រភពទឹកត្រូវភ្លើងឆេះ ដែលបង្ករការរាំងស្ទះយ៉ាងខ្លាំងដល់ការដុះលូតលាស់កូនឈើដោយធម្មជាតិ | • ពង្រឹងក្រុមល្បាតការពារភ្លើងឆេះព្រៃ<br>• បន្តផ្សព្វផ្សាយដល់សហគមន៍<br>• បង្កើនទំនាក់ទំនងជាមួយសហគមន៍មូលដ្ឋាន<br>• ដាំឈើធម្មជាតិស្តារបន្ថែមតាមតំបន់មាត់អូរ | • រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ស្តារព្រៃឈើឡើងវិញតាមរយៈការជំរុញដំណុះធម្មជាតិ និងការដាំបន្ថែមនៅតំបន់រិចរឹលខ្លាំង<br>• ការពារភ្លើងឆេះព្រៃ |

ធ្វើនៅភ្នំពេញ, ថ្ងៃទី........ខែ...........ឆ្នាំ២០២០

ប្រធានប្រតិបត្តិ

**ហុង លីណា**